គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY

លេខ ០០០៣/១០ គ.ស.ម

បំរើ ការពារ កសាង

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០

# សេចក្ដីថ្លែងការណ៍

ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ជាខួបគំរប់មួយឆ្នាំនៃការចុះហត្ថលេខារួមគ្នារវាងលោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស និងលោក សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី ស្ដីពីការបង្កើត" **ចលនានយោបាយប្រជាធិបតេយ្យដើម្បីការផ្លាស់ប្ដូរ**" ហើយគណបក្សទាំងពីរសម្រេចឈរឈ្មោះលើបញ្ជីតែមួយក្នុងការបោះឆ្នោតឆ្នាំ២០១២ និង២០១៣ ។ ក្រោយពីមានសេចក្ដីថ្លែងការណ៍រួមនេះមក ក្រុមការងាររបស់គណបក្សទាំងពីរបានជួបពិភាក្សាគ្នាជាញឹកញាប់ ប៉ុន្ដែពុំទាន់បានទទួលលទ្ធផលជាទីគាប់ចិត្ត និងតាមការទទូចចង់បានរបស់ប្រជាពលរដ្ឋខ្មែរនៅឡើយទេ ។ បច្ចុប្បន្នគណបក្សសិទ្ធិមនុស្សនៅតែទទូចរួបរួមគណបក្សនយោបាយទាំងអស់ដែលមាននិន្នាការប្រជាធិបតេយ្យឱ្យបានរួបរួមជាគណបក្សតែមួយ ដោយឈរលើគ្រឹះប្រជាធិបតេយ្យសេរីជាមូលដ្ឋាន ដោយផ្ដើមជាមួយនឹងគណបក្សសមរង្ស៊ី ។ ទទ្ទឹមនេះព្រោះតែការពិភាក្សាពុំទាន់ទទួលបានលទ្ធផល គណបក្សសិទ្ធិមនុស្សរក្សាសិទ្ធិក្នុងការពិភាក្សារួបរួមមិនថា គណបក្សណា ឬគស្សរជននយោបាយណាឡើយ ដែលមានបំណងចង់រួបរួមគ្នាក្នុងគ្រឹះប្រជាធិបតេយ្យសេរីដើម្បីចូលរួមក្នុងការបោះឆ្នោតឆ្នាំ២០១២ និង២០១៣ខាងមុខនេះស្របតាមសេចក្ដីប៉ងប្រាថ្នាដ៏ខ្លាំងក្លារបស់ប្រជាពលរដ្ឋខ្មែរដែលចង់ឃើញ ចង់បានឱ្យអ្នកប្រជាធិបតេយ្យរួបរួមគ្នាជាធ្លុងមួយក្នុងការបោះឆ្នោតនោះ ។ គណបក្សសិទ្ធិមនុស្សក៏ដូចជាពលរដ្ឋខ្មែរយល់ច្បាស់ថា មានតែអ្នកប្រជាធិបតេយ្យរួបរួមគ្នាជាគណបក្សតែមួយ ដោយឈរលើគោលការណ៍ និងគ្រឹះប្រជាធិបតេយ្យទេ ទើបយើងអាចយកជ័យជំនះ និងអាចជួយសង្គ្រោះសភាពការណ៍ប្រទេសជាតិដែលកំពុងតែឈានទៅរកជ្រោះមរណៈបាន ហើយជ័យជំនះរបស់អ្នកប្រជាធិបតេយ្យ គឺមានផ្លូវតែមួយគត់ គឺត្រូវតែរួបរួមគ្នាជាចាំបាច់បំផុត ។ ផ្ទុយទៅវិញបើអ្នកប្រជាធិបតេយ្យនៅពុំអាចរួបរួមគ្នាបាននោះ ទោះបីគណបក្សនីមួយៗបានទទួលសម្លេងខ្លះក៏ដោយ ក៏សម្លេងនោះពុំមានតម្លៃសម្រាប់ជួយសង្គ្រោះជាតិ និងប្រទេសបានឡើយ តែវាត្រឡប់ទៅជាការកំដរឱ្យប្រជាធិបតេយ្យក្លែងក្លាយដោយឱ្យគណបក្សដែលមានឫសគល់ពីកុម្មុយនីស្ដ បានកាន់កាប់ប្រទេស និងបន្ដបំផ្លាញធនធានធម្មជាតិ និងដីធ្លីស្រែចំការរបស់ពលរដ្ឋខ្មែរយើងស្របច្បាប់តែប៉ុណ្ណោះ ហើយទីបំផុត ព្រះរាជាណាចក្រកម្ពុជាយើងនឹងក្លាយទៅជាកម្ពុជាក្រោមទី២ និងពលរដ្ឋខ្មែរក្លាយជាអាណិកជនលើមាតុភូមិកំណើតរបស់ខ្លួនជាក់ជាពុំខាន និងពូជសាសន៍ខ្មែរត្រូវវិនាសសាបសូន្យពីសាកលលោកក្នុងពេលអនាគត ។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*

*ទូរស័ព្ទលេខ : ០១៦ ៤៣៥ ១០៦*

គណបក្ស សិទ្ធិមនុស្ស HUMAN RIGHTS PARTY